N.24
30.6.02

# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២១-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៦៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ១៧៦៧

២១-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/ ០៦០២/១៦៤ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ១៧៧៥

២១-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/ ០៦០២/១៦៥ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ១៧៨២

២១-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/ ០៦០២/១៦៦ ស្តីពីការតែងតាំង ឯកឧត្តម **ឌុល គឿន** ជាឧកញ៉ា ១៧៨៨

២៧-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/ ០៦០២/១៧៤ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **លីន ស៊ីវវិន** (LIN HSIU WEN )សញ្ជាតិដើមចិន កើតនៅក្រុងតៃប៉ិប្រទេសចិន ១៧៨៩


## I-រាជរដ្ឋាភិបាល

### ១~ អនុក្រឹត្យ


២៤-៦-២០០២ - អនុក្រឹត្យ លេខ ៥៩ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអាស៊ាន ១៧៩០

២៤-៦-២០០២ - អនុក្រឹត្យ លេខ ៦០ អនក្រ.បក ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃ ទី ២៩ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ១៧៩៣

២៤-៦-២០០២ - អនុក្រឹត្យ លេខ ៦១ អនក្រ.បក ស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១៧៩៥

២៤-៦-២០០២ - អនុក្រឹត្យ លេខ ៦២ អនក្រ.បក ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាននិងថ្លៃតែមប្រើសារពើពន្ធ ១៧៩៨

២៥-៦-២០០២ - អនុក្រឹត្យ លេខ ៣១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨០២

២៦-៦-២០០២ - អនុក្រឹត្យ លេខ ៣១៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨០៣


### ២~ សេចក្តីសំរេច


២៤-៦-២០០២ - សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង អង្កេតស្រាវជ្រាវករណី នាវាឈ្មោះ WINNER ១៨០៤

២៦-៦-២០០២ - សេចក្ដីសំរេចលេខ ៣៥ សសរ ស្ដីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង អង្កេតស្រាវជ្រាវករណី រណសិរ្សជាតិរំដោះកម្ពុជាក្រោម ១៨០៦

## II- ការិយាល័យបណ្ដាក្រសួង

### ១~ ទីស្ដីការរដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ

២៤-៦-២០០២ - ប្រកាសលេខ ០៩៩ ប្រក .ក.អ.ជ ស្ដីពីការតែងតាំងមន្ត្រីរាជការសំរាប់ គំរោងឥណទានធនាគារអភិវឌ្ឍន៍អាស៊ី និងគំរោងធនាគាពិភពលោក ១៨០៩

### ២~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២៥-៦-២០០២ - សេចក្ដីសំរេចលេខ ១៨៩ ក.ធ.ស.សរស្ដីពីការអនុញ្ញាតឱ្យកសាងវត្តថ្មីឈ្មោះថា "**វត្តសាលវន្ត**" នៃគណៈមហានិកាយ ឃុំ ច្រាច់ ស្រុកសែនជ័យ ខេត្តព្រះវិហារ ១៨១១

២៥-៦-២០០២ - សេចក្ដីសំរេចលេខ ១៩០ ក.ធ.ស សរស្ដីពីការអនុញ្ញាត ឱ្យកសាងវត្តថ្មីឈ្មោះថា "**វត្តឧក្សិណគីរី** " នៃគណៈមហានិកាយ ឃុំ ត្បែង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ១៨១២

២៥-៦-២០០២ - សេចក្ដីសំរេចលេខ ១៩១ ក.ធ.ស សរស្ដីពីការអនុញ្ញាតច្បាប់ឱ្យរុះរើព្រះវិហារចាស់កសាងថ្មីដែលស្ថិតនៅ " **វត្តលក្ខរាជា** " នៃគណៈមហានិកាយ ភូមិលក្ខរាជា ឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ១៨១៣

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៣

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ខិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងសម័យជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

# គ្រោងបន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ " ក " ដូចមានចែងក្នុងមាត្រា៣ នៃ ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ របស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រសុខាភិបាលកំរិតឧត្តម បំរើការងារក្នុងវិស័យសុខាភិបាល នៅតាមអង្គភាពជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈ របស់ក្រសួងស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានមុខងារក្នុងដំណែងគ្រប់គ្រង ដឹកនាំ សិក្សាស្រាវជ្រាវ និងផ្តល់យោបល់ផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តវេទសាស្ត្រ ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ មាន ១៤ ថ្នាក់ ។

**មាត្រា ៥.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ អាចកាន់មុខដំណែងគ្រប់គ្រង នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួងសុខាភិបាលដូចខាងក្រោម :៕.

- ឋានន្តរស័ក្តិទី ១ : អគ្គនាយកបច្ចេកទេសជំនាញ អគ្គាធិការបច្ចេកទេសជំនាញ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល

- ឋានន្តរស័ក្តិទី ២ : អគ្គនាយករងបច្ចេកទេសជំនាញ អគ្គាធិការរងបច្ចេកទេសជំនាញ សាកលវិទ្យាធិការរង អធិការបច្ចេកទេសជំនាញ ព្រឹទ្ធបុរសមហាវិទ្យាល័យ ប្រធាននាយកដ្ឋានបច្ចេកទេសជំនាញ

- ឋានន្តរស័ក្តិទី ៣ : ព្រឹទ្ធបុរសរងមហាវិទ្យាល័យ អនុប្រធាននាយកដ្ឋានបច្ចេកទេសជំនាញ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង និង មុខដំណែងបច្ចេកទេស វិទ្យាសាស្ត្រសុខាភិបាលឯទៀត ដែលមានថ្នាក់ស្មើនឹងមុខដំណែងខាងលើ នៃឋានន្តរស័ក្តិទីមួយៗ នៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា ៦.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជានិស្សិត និង ឬជាមន្ត្រីរាជការ ។ ចំនួនតំណែង ក្នុងការជ្រើសរើសសំរាប់បេក្ខជន ជានិស្សិត និងសំរាប់បេក្ខជនជាមន្ត្រីរាជការ តាមផ្នែកនីមួយៗ ត្រូវកំណត់ឡើង ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៧.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ ក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រតាមផ្នែកណាមួយ យ៉ាងទាបត្រឹមសញ្ញាប័ត្រសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ផ្នែកវេជ្ជសាស្ត្រ ផ្នែកឱសថសាស្ត្រ ឬផ្នែកទន្តវេទសាស្ត្រ ឬ សញ្ញាប័ត្រ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តវេទសាស្ត្រ ផ្សេងទៀតដែលមានតំលៃស្មើ ។

ចំពោះមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌ នៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។

## ជំពូកទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.-**

បេក្ខជន ដែលបានជ្រើសរើស តាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូង រៀបចំដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលជាន់ខ្ពស់ ។ល។

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវចាត់អោយទៅបំរើការងារ នៅតាមអង្គភាពសុខាភិបាល ខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំង ជាមន្ត្រីសុខាភិបាលជាន់ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីសុខាភិបាលជាន់ខ្ពស់ផ្នែកវេជ្ជសាស្ត្រ ត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៣ ហើយ មន្ត្រីសុខាភិបាលជាន់ខ្ពស់ផ្នែកផ្សេងទៀត ត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលជ្រើសរើសចេញពីមន្ត្រីរាជការរបស់ក្រសួងសុខាភិបាល ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ មន្ត្រីរាជការផ្សេងៗទៀត ត្រូវធ្វើកម្មសិក្សា សាកល្បងរយៈពេល ០៦ ខែ ។

មន្ត្រីសុខាភិបាលជាន់ខ្ពស់ដែលជ្រើសរើសតាមការប្រលងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត ។ ក្នុងករណីមិនទទួលបានជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការ ត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូងនិងកម្មសិក្សា សំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់អាចត្រូវតែងតាំង ក្នុងមុខតំណែងទំនេរណាមួយដូចមានកំណត់ក្នុងមាត្រា៣ និងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ ក្នុងមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១.-**

មន្ត្រីសុខាភិបាលជាន់ខ្ពស់ អាចត្រូវដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើមឬ ក្រៅដំណែងដើម ដើម្បីទៅបំរើការងារនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងទៀត តាមតម្រូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។ល។

# ជំពូកទី ៧

## ការដំឡើងឋានន្តរស័ក្តិ និង ការដំឡើងថ្នាក់

**មាត្រា ១២.-**

ការដំឡើងឋានន្តរស័ក្តិ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈសម្បត្តិផ្ទាល់ខ្លួនរបស់មន្ត្រីសាមី និង ល័ក្ខខ័ណ្ឌបណ្តុះបណ្តាល ដោយមានសញ្ញាប័ត្រជាមូលដ្ឋាន ។ ការដំឡើងឋានន្តរស័ក្តិ ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង ឬថ្នាក់ដែលមានសន្ទស្សន៍ បៀវត្សខ្ពស់ លើបន្ទាប់ ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

ត្រូវដំឡើងពីឋានន្តរស័ក្តិទី៣ ទៅឋានន្តរស័ក្តិទី ២ ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលស្ថិតនៅក្នុងថ្នាក់លេខ ១១ ឡើងទៅ និងមានលក្ខណៈ សម្បត្តិណាមួយដូចខាងក្រោម :

- មាននិក្ខេបបទ
- មានសញ្ញាប័ត្រ :
  - បណ្ឌិតវេជ្ជសាស្ត្រទូទៅ ឬបណ្ឌិតវេជ្ជសាស្ត្រឯកទេស
  - បណ្ឌិតឱសថសាស្ត្រ ឬបណ្ឌិតឱសថសាស្ត្រឯកទេស
  - បណ្ឌិតទន្តវេទនសាស្ត្រ ឬបណ្ឌិតទន្តវេទនសាស្ត្រឯកទេស

ឬសញ្ញាប័ត្រដទៃទៀតដែលមានតំលៃស្មើ ។

ត្រូវដំឡើងទៅក្នុងឋានន្តរស័ក្តិទី១ ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលស្ថិតនៅក្នុងថ្នាក់លេខ៧ឡើងទៅ នៃឋានន្តរស័ក្តិទី ២ ហើយដែលត្រូវទទួលការតែងតាំងជាសាស្ត្រាចារ្យមហាបរិញ្ញា ។

សញ្ញាប័ត្រឯកទេស ឬ សញ្ញាប័ត្រនានាខាងលើ ត្រូវមានការទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬ ក្រសួងអប់រំយុវជន និងកីឡា ។

ការដំឡើងពីឋានន្តរស័ក្តិ ទី៣ ទៅ ទី២ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការដំឡើងពីឋានន្តរស័ក្តិទី ២ ទៅទី ១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ១៣.-**

ចំនួនមន្ត្រីក្របខ័ណ្ឌ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ទៅតាមបរិមាណជាក់ស្តែង ដោយផ្អែកលើលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ និង ល័ក្ខខ័ណ្ឌបណ្តុះបណ្តាលដោយមានសញ្ញាប័ត្រជាមូលដ្ឋានដូចមានចែងក្នុងមាត្រា១២ ខាងលើ ។

**មាត្រា ១៤.-**

ការដំឡើងថ្នាក់មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។ល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- ប្រសិទ្ធិភាពក្នុងការដឹកនាំ និង គ្រប់គ្រង
- សាមគ្គីធមិ និងសីលធមិរស់នៅ ។

ត្រូវបានដំឡើងថ្នាក់មួយថ្នាក់ ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលក្រសួងបានចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាល រយៈពេលយ៉ាងតិច ០១ឆ្នាំ ដោយមានលិខិតបញ្ជាក់ការសិក្សា វិញ្ញាបនប័ត្រ ឬ សញ្ញាប័ត្រចេញដោយ គ្រឹះស្ថានបណ្តុះបណ្តាលនោះ ។

ការដំឡើងថ្នាក់មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសក្រសួងសុខាភិបាល ស្របតាមឋានន្តរស័ក្តិនៃមន្ត្រីសាមី ។

**មាត្រា ១៥.-**

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងពំលែងកពោនៃសន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យ លេខ នស /រកត/ ១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦.-**

មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានស្នាដៃពិសេស ឬ ទទួលជោគជ័យក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រថ្មី ត្រូវទទួលការលើកសរសើរ ឬ រង្វាន់លើកទឹកចិត្តពីរាជរដ្ឋាភិបាល តាមករិតស្នាដៃជាក់ស្តែង ក្រៅពីការដំឡើងថ្នាក់ឬឋានន្តរស័ក្តិ ។

ក្នុងពេលបំរើការងារ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រសកលវិទ្យាល័យ ត្រូវដំឡើងថ្នាក់មួយថ្នាក់ ជាស្វ័យប្រវត្តិ ។

**មាត្រា ១៧.-**

មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ ឆ្នាំ ។

**មាត្រា ១៨.-**

សញ្ញាស័ក្តិ និង ឯកសណ្ឋាន សំរាប់មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រខាងវិស័យសុខាភិបាល ហើយបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាល នៅរដ្ឋបាលកណ្តាល និងខេត្ត ក្រុង របស់ក្រសួង ស្ថាប័នរដ្ឋ ផ្អែកតាមលក្ខណៈសម្បត្តិផ្ទាល់ខ្លួនរបស់មន្ត្រីរាជការ ដូចខាងក្រោម :

- បញ្ចូលក្នុងឋានន្តរស័ក្តិទី៣ ចំពោះមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រចេញពីមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ ឬសញ្ញាប័ត្រសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ឬសញ្ញាប័ត្រផ្សេងទៀតដែលមានតំលៃស្មើ ។
- បញ្ចូលក្នុងឋានន្តរស័ក្តិ ទី២ ចំពោះមន្ត្រីរាជការដែល :

  - មាននិក្ខេបបទ
  - មានសញ្ញាប័ត្រឯកទេស
  - ជាសាស្ត្រាចារ្យ ដែលតែងតាំងដោយក្រសួងសុខាភិបាល រយោយបង្រៀន និង ណែនាំអនុវត្តមុខវិជ្ជាឯកទេសណាមួយ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង អង្គភាពធ្វើកម្មសិក្សាអនុវត្តន៍ ហើយមានបទពិសោធន៍ ការងារយ៉ាងតិច ១០ ឆ្នាំ
  - ជាប្រធាន ឬ អនុប្រធានអាសនៈសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
  - ជាមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានសមត្ថភាពខ្ពស់ ឆ្លងកាត់ការវាយតំលៃរបស់គណៈកម្មការបង្កើតឡើងដោយក្រសួងសុខាភិបាល ។

- បញ្ចូលក្នុងឋានន្តរស័ក្តិទី១ ចំពោះមន្ត្រីរាជការដែលបានទទួលការតែងតាំងជាសាស្ត្រាចារ្យដោយការប្រលងតាមនីតិវិធីដែលឆ្លងកាត់ការវាយតម្លៃ របស់ក្រុមប្រឹក្សាមេប្រយោគបង្កើតឡើងដោយក្រសួងសុខាភិបាល ។

**មាត្រា ២០.-**

មុខតំណែងគ្រប់គ្រងនីមួយៗ ដែលត្រូវអនុវត្តតាមគោលការណ៍ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ខ្ពស់ជាងគេ មិនមានប្រតិសកម្ម ទៅលើមុខដំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយទេ លើកលែងតែមានការចាំបាច់ ដែលជាសមត្ថកិច្ចរបស់ក្រសួង ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។/៚

**មាត្រា ២២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។៚

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នសរ.០២.០៦.០០១៧៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៤

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌ មន្ត្រីសុខាភិបាលមធ្យមរបស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ " ខ " ដូចមានចែង ក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧ / ២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសសុខាភិបាលកំរិតមធ្យម បំរើការងារក្នុងវិស័យសុខាភិបាល តាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មានមុខងារជួយដល់មន្ត្រីសុខាភិបាលជាន់ខ្ពស់ក្នុងការសំរេចអនុវត្តការងារ និងអាចបំពេញមុខដំណែងដឹកនាំកំរិតមធ្យម ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង មុខដំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យម ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យម ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យមមាន ១៤ ថ្នាក់ ។ល។

**មាត្រា ៥.-**

មន្ត្រីសុខាភិបាលមធ្យម អាចកាន់មុខតំណែងគ្រប់គ្រង នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួងសុខាភិបាល ដូចខាងក្រោម :

- ឋានន្តរស័ក្តិទី ១ : ប្រធានការិយាល័យជំនាញនៅថ្នាក់កណ្តាល អនុប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង
- ឋានន្តរស័ក្តិទី ២ : អនុប្រធានការិយាល័យជំនាញនៅថ្នាក់កណ្តាល ប្រធានការិយាល័យជំនាញនៃមន្ទីរសុខាភិបាលខេត្ត ក្រុង
- ឋានន្តរស័ក្តិទី ៣: អនុប្រធានការិយាល័យជំនាញនៃមន្ទីរសុខាភិបាលខេត្ត ក្រុង ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ

និងមុខដំណែងឯទៀតដែលមានថ្នាក់ស្មើ នឹងមុខតំណែងខាងលើនៃឋានន្តរស័ក្តិនីមួយៗនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៦.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌ មន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និង ឬ ជាមន្ត្រីរាជការ ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជានិស្សិតឬសំរាប់បេក្ខជន ជាមន្ត្រីរាជការ តាមផ្នែកនីមួយៗ ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៧.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត២៨ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រផ្នែកណាមួយ យ៉ាងទាប ដូចខាងក្រោម :

- សញ្ញាប័ត្រគិលានុបដ្ឋាក គិលានុបដ្ឋាយិកា មធ្យម
- សញ្ញាប័ត្រឆ្មបមធ្យម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម
- សញ្ញាប័ត្រព្យាបាលដោយចលនាមធ្យម

និងសញ្ញាប័ត្រជំនាញផ្នែកបច្ចេកទេសផ្សេងៗទៀត និងអមវេជ្ជសាស្ត្រឯទៀត ដែលមានតំលៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌ ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌ នៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤០ ឆ្នាំ ។ ស.រ.

# ជំពូកទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.-**

បេក្ខជន ដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិតនិងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលមធ្យម ។

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលមធ្យម ត្រូវចាត់អោយទៅបំរើការងារ នៅតាមអង្គភាពសុខាភិបាល ខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំងជាមន្ត្រីសុខាភិបាលមធ្យមកម្មសិក្សា ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលមធ្យម ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីសុខាភិបាលមធ្យម ដែលជ្រើសរើសចេញពីមន្ត្រីរាជការរបស់ក្រសួងសុខាភិបាលពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ មន្ត្រីរាជការផ្សេងៗទៀតត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ ខែ ។

មន្ត្រីសុខាភិបាលមធ្យម ដែលបានជ្រើសរើសតាមការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិ ទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលមធ្យម ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត ។ ក្នុងករណីមិនទទួលបានជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សា សំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

# ជំពូកទី ៥
## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានកំណត់ក្នុងមាត្រា៣ និងមាត្រា៥ ខាងលើ ។ល។

# ជំពូកទី ៦

## ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១.-**

មន្ត្រីសុខាភិបាលមធ្យម អាចត្រូវដាក់អោយស្ថិតក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែងដើម ដើម្បីទៅបំរើការនៅក្រសួង ស្ថាប័ន ឬអង្គភាពផ្សេងណាមួយ តាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

# ជំពូកទី ៧

## ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិ

**មាត្រា ១២.-**

មន្ត្រីសុខាភិបាលមធ្យម ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុង មាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិ ជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- ប្រសិទ្ធិភាពក្នុងការដឹកនាំ និង គ្រប់គ្រង
- សាមគ្គីធម៌ និង សីលធម៌រស់នៅ ។

ការដំឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១៣.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ចំនួនតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោម :

- ៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣ ។ល។

ការដំឡើងឋានន្តរស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងការវាយតំលៃ របស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលបន្តនៅក្នុង ឬក្រៅប្រទេស។

ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិនៃ មន្ត្រីសុខាភិបាលមធ្យម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១៤.-**

សន្ទស្សន៍ សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃ សន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំរបស់មន្ត្រីរាជការ ។

## ជំពូកទី ៨

## បនប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

មន្ត្រីសុខាភិបាលមធ្យម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលបន្តរយៈពេលសរុប យ៉ាងតិច ០៦ ខែ ក្នុងជំនាញរបស់ខ្លួន ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សា ត្រូវទទួលការដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស ។

**មាត្រា ១៦.-**

មន្ត្រីសុខាភិបាលមធ្យម ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង របស់ក្រសួងស្ថាប័នរដ្ឋ ហើយដែលមានសញ្ញាប័ត្រណាមួយ ដូចមានចែងក្នុងមាត្រា៧ នៃព្រះរាជក្រឹត្យនេះ ។ល។

**មាត្រា ១៨.-**

មន្ត្រីសុខាភិបាលមធ្យម ដែលបានតែងតាំងរួចហើយក្នុងមុខតំណែងគ្រប់គ្រងណាមួយ ត្រូវអនុញ្ញាតអោយបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ត្រូវផ្លាស់ប្តូរមុខតំណែងដែលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២១.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។៚

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ចករ**

**នរោត្តម សីហនុ**

នរក.០៤,០៦.០០១៧៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៥

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមរបស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ "គ" ដូចមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧ / ២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសសុខាភិបាលកំរិតបឋម បំរើការងារក្នុងវិស័យសុខាភិបាល តាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង និង គ្រឹះស្ថានសាធារណៈ របស់ក្រសួង ស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម មានមុខងារក្នុងការប្រតិបត្តិបច្ចេកទេសជំនាញ សុខាភិបាល ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង ថ្នាក់តំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌ មន្ត្រីសុខាភិបាលបឋម មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋមមាន ១៤ ថ្នាក់ ។/.

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងឬ ជាមន្ត្រីរាជការ ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជាសិស្ស និស្សិត និង ជាមន្ត្រីរាជការតាមផ្នែកនីមួយៗត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៦.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ ក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រផ្នែកណាមួយ យ៉ាងទាប ដូចខាងក្រោម :

- សញ្ញាប័ត្រ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាបឋម
- សញ្ញាប័ត្រឆ្មបបឋម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម

និងសញ្ញាប័ត្រជំនាញ ផ្នែកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្រឯទៀត ដែលមានតំលៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ចំពោះមន្ត្រី ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌនៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៣៥ ឆ្នាំ ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជន ដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំឡើងដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលបឋម ។

**មាត្រា ៨.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលបឋម ត្រូវចាត់អោយទៅបំរើការងារនៅតាមអង្គភាពសុខាភិបាលខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវ តែងតាំងជាមន្ត្រីសុខាភិបាលបឋមកម្មសិក្សាដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីមន្ត្រីរាជការ ត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ ខែ ។ល។

មន្ត្រីសុខាភិបាលបឋម ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលបឋម ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត ។ ក្នុងករណីដែលមិនទទួលជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្ស និស្សិតត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សា សំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៩.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានកំណត់ក្នុងមាត្រា ៣ ខាងលើ ។

## ជំពូកទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១០.-**

មន្ត្រីសុខាភិបាលបឋម អាចត្រូវដាក់អោយស្ថិតក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែងដើម ដើម្បីទៅបំរើការនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងណាមួយ តាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូកទី ៧

## ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រីសុខាភិបាលបឋម ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុង មាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិ ជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីធម៌ និង សីលធម៌រស់នៅ ។ ល។

ការដំឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១២.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវដំឡើងទៅ ក្នុងថ្នាក់ដែលមានសន្ទស្សន៍ខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ចំនួនដំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ ដូចខាងក្រោម :

- ៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣ ។

ការដំឡើងឋានន្តរស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងការវាយតំលៃ របស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលបន្តនៅក្នុង ឬក្រៅប្រទេស។

ការដំឡើងថ្នាក់និងការដំឡើងឋានន្តរស័ក្តិនៃមន្ត្រីសុខាភិបាលបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

សន្ទស្សន៍ សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ។

## ជំពូកទី ៨

## បន្តប្បញ្ញត្តិដោយឡែក

**មាត្រា ១៤.-**

មន្ត្រីសុខាភិបាលបឋម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលបន្តរយៈពេលសរុប យ៉ាងតិច ០៦ ខែ ក្នុងជំនាញរបស់ខ្លួន ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សា ត្រូវទទួលការតំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស។

**មាត្រា ១៥.-**

មន្ត្រីសុខាភិបាលបឋម ត្រូវដាក់ឱ្យចូលនិវត្តន៍ ពេលដល់អាយុ ៥៨ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។ ល.ក.

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលកណ្ដាល និង ខេត្ត ក្រុង របស់ក្រសួង ស្ថាប័នរដ្ឋ ហើយដែលមានសញ្ញាប័ត្រណាមួយ ដូចមានចែងក្នុងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៧.-**

មន្ត្រីសុខាភិបាលបឋម ដែលបានតែងតាំងរួចហើយក្នុងមុខតំណែងគ្រប់គ្រងណាមួយ ត្រូវអនុញ្ញាតឱ្យបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ត្រូវផ្លាស់ប្ដូរមុខតំណែង ដែលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២០.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។ល។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស/រកត.០២.០៦.០០១៧៧

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] សាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៦

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**ឯកឧត្តម ឌូល គឿន**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២*

៣៧ល-០២-០៦-០០១៧៤

លេខៈ១៤៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី ឆាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៧៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីន ស៊ីវវិន** ( LIN HSIU WEN ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៥៦ នៅក្រុងតៃប៉ិ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ១៥០ ច.ល

ដើម្បីចម្លងចែក

៣រល-០២.០៦-០០១៨៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ..៥៥..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យអាស៊ាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ .នស .៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ស៊ុន សុវណ្ណារិទ្ធិ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យអាស៊ាន" " ASEAN UNIVERSITY " ហៅកាត់ជាភាសាខ្មែរ " ស.អ " និងហៅកាត់ជា ភាសាអង់គ្លេស "A.U " ។

សាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំងគោល ស្ថិតនៅអាគារលេខ ១ ផ្លូវលេខ ១៣៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យអាស៊ានធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលសិក្សាក្រោម ២ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨៤ ក្រេឌីត ។
- ថ្នាក់បរិញ្ញាប័ត្រសិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦៥ ក្រេឌីត ។
- ថ្នាក់ម៉ាស្ទ័រសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ។
- ថ្នាក់បណ្ឌិតសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។

**មាត្រា ៣ :** សាកលវិទ្យាល័យអាស៊ានមាន :

១- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង ទេសចរណ៍

២- មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច

៣- មហាវិទ្យាល័យ ពត៌មានវិទ្យា

៤- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ

៥- មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ជំនាញវិជ្ជាជីវៈ រយៈពេលសិក្សាក្រោម ២ឆ្នាំ

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យអាស៊ាន មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាសិក្សាមួយដែលសមាជិកក្រុមប្រឹក្សានេះមានសញ្ញាប័ត្រកំរិតបណ្ឌិត សំរាប់ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុតបានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនដែលមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រ ដែលមាន តំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជន ដែលមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រ ដែលមាន តំលៃស្មើ ។

សាកលវិទ្យាល័យត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀនទៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាស៊ានមានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិក បំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យអាស៊ាន ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះបំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យអាស៊ាន មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាម អនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនដំណឹង"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១/៩៧/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៨៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- យោងតាមតាមសំណើរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់

## ស ំ រេ ច

**មាត្រាតែ ១.-** ត្រូវបានកែសម្រួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋានដូចខាងក្រោម ។

tom225

**មាត្រា ៨ ថ្មី.-**

ក្រុមប្រឹក្សា ឃុំ សង្កាត់ ទទួលខុសត្រូវការងារអត្រានុកូលដ្ឋានក្នុងដែនដី ឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥៩ ថ្មី.-**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាពត្រូវទៅសុំសាលក្រម ពីតុលាការ ខេត្ត ក្រុង សាមី រួចយកសាលក្រមនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតអោយប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់នៅ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៤ នៃអនុក្រឹត្យ លេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង យូ ហុកគ្រី**

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- កាលប្បវត្តិ ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦១...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកំណត់ប្រាក់បំណាច់ចំពោះសមាជិក

# ក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០២ តទៅ ប្រាក់បំណាច់ប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកំណត់ដូចខាងក្រោម :

- ប្រធានក្រុមប្រឹក្សា និង ជាមេឃុំ ចៅសង្កាត់ ក្នុងមួយនាក់ ១០០.០០០ រៀល ក្នុងមួយខែ ។
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលមុខតំណែងជាជំទប់ទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ ក្នុងមួយនាក់ ៨០.០០០ រៀល ក្នុងមួយខែ ។
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនស្ថិតក្នុងមុខតំណែងខាងលើក្នុងមួយនាក់ ៧០.០០០ រៀល ក្នុងមួយខែ ។

**មាត្រា ២.-** សំរាប់ឆ្នាំថវិកា ២០០២ ត្រូវបានអនុញ្ញាតអោយផ្ទេរថវិការដ្ឋសំរាប់ឧបត្ថម្ភ តុល្យភាពភូមិ ឃុំ ដែលបានគ្រោងផ្តល់អោយថវិកាខេត្ត ក្រុង ចូលគណនីមូលនិធិឃុំ សង្កាត់ នៅរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ប្រាក់បំណាច់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣.-** ប្រាក់បំណាច់របស់ប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ ជំទប់ទី១ ជំទប់ទី២ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀត ត្រូវចាប់អនុវត្តក្រោយពីមានប្រកាសទទួលស្គាល់ជាផ្លូវការរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

**ស ខេង** **យូ ហុកគ្រី** **គាត ឈន់**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦២ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍សារពើពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២៣ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតតែមប្រិ៍សារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៧៦អនក្រ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រិ៍
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**មាត្រា ១-**

ត្រូវបានកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទដូចខាងក្រោម ÷

ក- ខេត្តរតនគីរី-មណ្ឌលគីរី-ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ :

| | |
|---|---|
| - ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | កំណត់ ២០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់កំណើត | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់មរណភាព | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |

ខ- ខេត្ត-ក្រុង ក្រៅពីខេត្តទាំង ០៥ ខាងលើ :

| | |
|---|---|
| - ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់កំណើត | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់មរណភាព | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |

**មាត្រា ២ .-**

ថ្លៃតែមប្រើសារពើពន្ធសំរាប់បិទលើក្រដាសអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម .÷

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ កំណត់ ១.០០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត កំណត់ ៣០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត កំណត់ ៣០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ កំណត់ ១.៥០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ កំណត់ ១.៥០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព កំណត់ ៤០០ រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លងឬ សម្រង់សំបុត្របញ្ជាក់មរណភាព កំណត់ ៤០០ រៀល ក្នុង ១ ច្បាប់

**មាត្រា ៣ .-**

ចំណូលដែលឃុំ សង្កាត់ ប្រមូលបានពីការលក់ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវចាត់ជាចំណូលផ្ទាល់របស់ថវិកាឃុំ សង្កាត់ ។

**មាត្រា ៤ .-**

ក្រសួងមហាផ្ទៃមានភារកិច្ចបោះពុម្ពក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សំរាប់ផ្គត់ផ្គង់ដល់អាជ្ញាធរដែលមានភារកិច្ចអនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាន ។

**មាត្រា ៥ .-**

ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ក្នុងករណីចាំបាច់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងបន្ថែមទៀត ។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២..*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

**ស ខេង** **យូ ហុកគ្រី** **គាត ឈន់**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣១៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គនាយកវិទ្យុ-ទូរទស្សន៍បាយ័ន

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឧកញ៉ា **ស៊ីម ឆៃ** និង លោកជំទាវ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងផែថ្មពីរ និង ផ្លូវលំ ០១ ខ្សែ ជូនប្រជាពលរដ្ឋ ឃុំកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ចំនួន ២១.៦៦៧.១៨ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៧១៨...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូននាយទាហាន ០៦ រូប នៃក្រុមបេសកកម្មសហប្រតិបត្តិការយោធា និងការពារបារាំងប្រចាំនៅកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការជួយកសាងនិងធ្វើសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ ដូចមាននាមខាងក្រោម ÷

១-វរសេនិយទោ RENAUDIN Daniel ទីប្រឹក្សាអមសេនាធិការ កងរាជអាវុធហត្ថ
២-វរសេនិយទោ GARCIA Philippe ទីប្រឹក្សាអមនាយកសាលានាយទាហានថ្នាតពង
៣-វរសេនិយទោ CASSEN Jean ទីប្រឹក្សាអមទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន
៤-វរសេនិយត្រី LESAGE Frédéric ទីប្រឹក្សាអមកម្មសិក្សាថ្នាក់មេបញ្ជាការកងវរសេនាតូច
៥-អនុសេនិយឯក SUCHET Olivier ទីប្រឹក្សាអមយោធាចារ្យឯកទេស សាលានាយទាហាន
៦-អនុសេនិយឯក BERTUCCI Dominique ទីប្រឹក្សាអមកងពលតូចសាលានាយទាហានសកម្ម

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៤ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង អង្កេតស្រាវជ្រាវករណី នាវាឈ្មោះ WINNER

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ .-**

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអង្កេតស្រាវជ្រាវ ករណីនាវាឈ្មោះ WINNER ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ទោ នេត្រ សាវឿន | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ ផល | ប្រធាននាយកដ្ឋានពត៌មានទូទៅ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-លោក ឧត្តមសេនីយ៍ត្រី សៅ រ៉ានី | ប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៤-លោក ឧត្តមសេនីយ៍ត្រី មៀច សុផាន់ណា | ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | **សមាជិក** |

៥-លោក តាំង លាងខ័ណ្ឌ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦-លោក ខ្ញុំម នារារិទ្ធ ប្រធានការិយាល័យច្បាប់ នាយកដ្ឋាននីតិកម្ម ក្រសួងពាណិជ្ជកម្ម សមាជិក

**ប្រការ ២ .-**

គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ច :

-ពិនិត្យ ស្រាវជ្រាវនៅក្នុងក្រុមហ៊ុន CAMBODIA SHIPPING CORPORATOIN(CSC) នូវឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការចុះបញ្ជីឈ្មោះនាវា និងការអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជា ។ មានប៉ុន្មានគ្រឿងដែលបានចុះបញ្ជី ។

-ពិនិត្យ ស្រាវជ្រាវឯកសារផ្សេងៗពាក់ព័ន្ធនឹងការបង់ពន្ធ និងការបង់ចំណូលផ្សេងទៀត ប្រសិនបើមាន ចូលថវិការដ្ឋ ក្នុង១ឆ្នាំៗ បានប៉ុន្មាន ។

-ពិនិត្យ ស្រាវជ្រាវលក្ខណៈវិនិច្ឆ័យដែលបានកំណត់សំរាប់នាវានីមួយៗ ដើម្បីអាចចុះបញ្ជី និងអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជាបាន ។

-ទំនាក់ទំនងជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន សុំបញ្ជីឈ្មោះនាវាធំៗទាំងអស់ ដែលក្រសួងបានចុះបញ្ជី និងអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជា ។

-ក្រោយពីប្រមូលបានពត៌មានសព្វគ្រប់ គណៈកម្មការត្រូវប្រជុំវាយតំលៃ រួចរាយការណ៍លទ្ធផលការងាររបស់ខ្លួន ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីរាយការណ៍បន្តជូនសម្តេចនាយករដ្ឋមន្ត្រី ពិនិត្យ និងមានវិធានការតាមការជាក់ស្តែង ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសមាសភាពដូចមានចែងក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៥ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង
## អង្កេតស្រាវជ្រាវ ករណីរណសិរ្សជាតិរំដោះកម្ពុជាក្រោម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១:-**

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអង្កេតស្រាវជ្រាវករណីរណសិរ្សជាតិរំដោះកម្ពុជាក្រោម ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ **ប្រធាន**

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **មល រឿប** នាយរងសេនាធិការចំរុះ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា **អនុប្រធាន**

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ **សមាជិក**

៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ **សមាជិក**

៦-លោក ឧត្តមសេនីយ៍ត្រី **ជុំ ហាក់** នាយរងសេនាធិការ និងជាប្រធានការិយាល័យទី២ នៃកងទ័ពជើងគោក **សមាជិក**

៧-លោក ឧត្តមសេនីយ៍ត្រី **ថាច គឹមហោ** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ **សមាជិក**

**ប្រការ២៖-**

គណៈកម្មការចំរុះអន្តរក្រសួងនេះមានភារកិច្ច ៖

-ពិនិត្យស្រាវជ្រាវអង្គការចាត់តាំងទាំងខាងនយោបាយ និងយោធារបស់រណសិរ្សជាតិរំដោះកម្ពុជាក្រោម ។

-ពិនិត្យស្រាវជ្រាវប្រមែប្រមូលឯកសារវត្ថុតាងផ្សេងៗ ដែលទាក់ទងដល់សកម្មភាពរណសិរ្សជាតិរំដោះកម្ពុជាក្រោម ។

-ទំនាក់ទំនងសហការជាមួយស្ថាប័នផ្សេងៗ និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រមែប្រមូល ឯកសារដែលទាក់ទងដល់រណសិរ្សរំដោះកម្ពុជាក្រោម ។

-ក្រោយពីប្រមូលបានពត៌មានសព្វគ្រប់ គណៈកម្មការត្រូវប្រជុំវាយតម្លៃ រួចរាយការណ៍លទ្ធផលការងារ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីរាយការណ៍បន្តជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីពិនិត្យនិងមានវិធានការតាមការជាក់ស្តែង ។

**ប្រការ៣ៈ-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក និងសមាសភាពដូចចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០២

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

**លេខ..០៩៩..ឋ.ក.. ក.អ.ជ**

ភ្នំពេញ, ថ្ងៃទី..24..ខែមិថុនា......ឆ្នាំ200.2

# ប្រកាស

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### សំរាប់គំរោងឥណទានធនាគារអភិវឌ្ឍន៍អាស៊ី និងគំរោងធនាគារពិភពលោក

### រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស /រកម /០១៩៦ /១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញ កិច្ចព្រមព្រៀងឥណទានលេខ ១៨២៤ - CAM (SF) ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគំរោងស្តារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដែលខូចខាតដោយទឹកជំនន់.
- បានឃើញ កិច្ចព្រមព្រៀងឥណទានលេខ ៣៤៧២- (KH) ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០១. រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ស្តីពីគំរោងស្តាឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដែលខូចខាតដោយទឹកជំនន់ ។
- បានឃើញ សំណើតែងតាំងមន្ត្រីរាជការ លេខ ០៦២ អជប.ភព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ.
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**ប្រការ១** : តែងតាំង លោក **ឯម សុភី** ជាប្រធានអង្គភាពអនុវត្តគំរោងរាជធានីភ្នំពេញ (PIU/PHP) ជំនួសលោក **សម ថន** ដែលបានទទួលមរណៈភាពនៅថ្ងៃទី៧ ខែមិនា ឆ្នាំ២០០២ សំរាប់គំរោងស្តារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលខូចខាតដោយ ទឹកជំនន់ ឥណទានលេខ ១៨២៤ - **CAM (SF)** និងគំរោងស្តារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធ ដែលខូចខាតដោយទឹកជំនន់ ឥណទានលេខ ៣៤៧២ - **(KH)** ។



អាស័យដ្ឋាន : កាច់ជ្រុងវិថីលេខ ១៦៩ និងមហាវិថីសូរ្យៀត ទូរស័ព្ទលេខ : (023) 426 850

**ប្រការ២:** រាល់សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** អគ្គនាយកដ្ឋានទាំងពីរ អគ្គាធិការដ្ឋាន ខុទ្ទកាល័យ គ្រប់នាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ និងសាម៉ីជនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

លី-ធុជ

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចមានចែងក្នុងប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ១៨៥ ក.ធ.សគរ

## សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឱ្យកសាងវត្តថ្មីឈ្មោះថា " វត្តសាលវ័ន្ត "
នៃគណៈមហានិកាយ ឃុំ ប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ

### រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ព្រះវិហារ លេខ ៦៦៩ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រះវិហារ លេខ ៩៧/០២ ធណ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

-យោងតាមចំណាររបស់អភិបាលស្រុក ជ័យសែន លេខ ១៤ ស.ណ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០២.

-តាមសំណើសុំរបស់ ពុទ្ធបរិស័ទ និងមេឃុំ ប្រាច់ ស្រុកជ័យសែន ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០២.

### សំ រេ ច

**ប្រការមួយ:** អនុញ្ញាតឱ្យកសាងវត្តថ្មី ឈ្មោះ " វត្តសាលវ័ន្ត " នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុង ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ដោយមានក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ :** វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និង ធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធ សាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និង រីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តព្រះវិហារ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

អ៊ុន_ចិសាអ៊ីម

**ចម្លងជូន-ជូន:**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីថ្វាយ-ជូនជ្រាប "
-រាជកិច្ច " ដើម្បីចុះផ្សាយ "
-សាលាខេត្តព្រះវិហារ
-អភិបាលស្រុកជ័យសែន
-ដូចប្រការបី
" ដើម្បីសហការអនុវត្ត "
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ ១៥០ ក.ធ.ស [illegible]

# សេចក្តីសំរេច

**ស្តីពីការអនុញ្ញាតឱ្យកសាងវត្តថ្មីឈ្មោះថា " វត្តឧត្តរគិរី "**
**នៃគណៈមហានិកាយ ឃុំភ្នំត្បែង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ**

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ព្រះវិហារ លេខ ៧៩៩.ចណាលជ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រះវិហារ លេខ ៥៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០១.

-យោងតាមចំណាររបស់អភិបាលស្រុក សង្គមថ្មី លេខ ៣៣ ស.ណ ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០១.

-តាមសំណើសុំរបស់ ពុទ្ធបរិស័ទ និងមេឃុំ ភ្នំត្បែងI ស្រុកសង្គមថ្មី ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០០១.

## ស ំ រេ ច

**ប្រការមួយ:** អនុញ្ញាតឱ្យកសាងវត្តថ្មី ឈ្មោះ "**វត្តឧត្តរគិរី**" នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុង ឃុំភ្នំត្បែងI ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដោយមានក្បាច់រចនា ជាប្រពៃណីវប្បធម៌របស់ជាតិ ។

**ប្រការពីរ :** វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និង ធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធ សាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និង រីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តព្រះវិហារ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

អ៊ិន-ទីសាអ៊ីម

**ចម្លងជូន:**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីថ្វាយ-ជូនជ្រាប "
-រាជកិច្ច " ដើម្បីចុះផ្សាយ "
-សាលាខេត្តព្រះវិហារ
-អភិបាលស្រុកសង្គមថ្មី
-ដូចប្រការបី
" ដើម្បីសហការអនុវត្ត "
ឯកសារ-កាលប្បវត្ត

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ ៧៨១ ក.ធ.សកច

# សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឲ្យ ប់ឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មីដែលស្ថិតនៅ "វត្តលក្ខរាជា" នៃគណៈមហានិកាយ ភូមិលក្ខរាជា ឃុំកំពង់ចក ស្រុកវ៉ដួល ខេត្តស្វាយរៀង

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ស្វាយរៀង លេខ ២០៧ ចប.សកិ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០០២.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង លេខ ៥៤ មធក.ស្វរ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០២.

-យោងតាមចំណាររបស់អភិបាលស្រុករំដួល លេខ ១១២ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០២.

-តាមសំណើសុំកសាងវត្ត របស់ចៅអធិការ និងអាចារ្យ គណៈកម្មការ វត្ត លក្ខរាជា ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២.

## សំរេច

**ប្រការមួយៈ** អនុញ្ញាតឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មី "វត្តលក្ខរាជា" នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុង ភូមិលក្ខរាជា ឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ដោយរក្សានូវក្បាច់រចនា ជាវប្បធម៌របស់ជាតិ ។

**ប្រការពីរ :** ព្រះវិហារថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត និង ប្រពៃណីពុទ្ធសាសនាព្រមទាំងច្បាប់របស់រដ្ឋ ឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

**ចម្លងជូន ៖**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

"ដើម្បីថ្វាយ-ជូនជ្រាប"

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-សាលាខេត្តស្វាយរៀង

-អភិបាលស្រុករំដួល

-ដូចប្រការបី

"ដើម្បីសហការអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

ជា_សាវឿន